# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ការអញ្ជើញឲ្យដាក់សំណើដេញថ្លៃ
## ការអញ្ជើញលេខៈ CDRR/PVG-ROAD-1406
## លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍
## តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប)
## គម្រោងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅសហគមន៍មូលដ្ឋាន
## សមាសភាព C

មូលនិធិលេខ:9178-CAM

មានបំណងជ្រើសរើសអ្នកទទួលការដើម្បីអនុវត្តការងារសាងសង់/ស្តារឡើងវិញហេដ្ឋារចនាសម្ព័ន្ធដូចខាងក្រោមៈ

ឈ្មោះកិច្ចសន្យាៈ **ជួសជុលផ្លូវលំដីសក្រាលខ្សាច់ក្នុំប្រវែង ៦៣៥ ម៉ែត្រ ទទឹង ៥.៥ ម៉ែត្រ និងដាក់លូភ្លោះ ២កន្លែង ស្ថិតក្នុងភូមិស្វាយអណ្តូង ឃុំកោះសំពៅ ស្រុកពាមជរ ខេត្តព្រៃវែង។**

១. រាជរដ្ឋាភិបាលកម្ពុជាបានទទួលជំនួយឥតសំណងពីធនាគារអភិវឌ្ឍន៍អាស៊ីសម្រាប់ ការចំណាយលើគម្រោងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅសហគមន៍មូលដ្ឋាន ហើយមានបំណងប្រើប្រាស់មួយផ្នែកនៃជំនួយឥតសំណងនេះសម្រាប់ចំណាយលើកិច្ចសន្យា **គម្រោងជួសជុលផ្លូវលំដីសក្រាលខ្សាច់ក្នុំប្រវែង ៦៣៥ ម៉ែត្រ ទទឹង ៥.៥ ម៉ែត្រ និងដាក់លូភ្លោះ២កន្លែង (CDRR/PVG-ROAD-1406)**។

២. តម្លៃប៉ាន់ស្មានសម្រាប់កិច្ចសន្យានេះគឺ **30,684.57 ដុល្លាសហរដ្ឋអាមេរិក** (បីម៉ឺនប្រាំមួយរយប៉ែតសិបបួនដុល្លារ ហាសិបប្រាំពីរសេន)។

៣. កាលវិភាគសាងសង់មានរយៈពេល **៣ខែ** គិតចាប់ពីកាលបរិច្ឆេទចាប់ផ្តើម។

៤. អ្នកទទួលការមានសិទ្ធិ និងលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលមានចំណាប់អារម្មណ៍ត្រូវបានអញ្ជើញឱ្យមកទទួលយកឯកសារដេញថ្លៃចំនួនមួយច្បាប់ដោយឥតគិតថ្លៃនៅអាស័យដ្ឋានខាងក្រោម។

៥. ដើម្បីក្លាយជាអ្នកដែលមានសិទ្ធិអ្នកទទួលការត្រូវ ៖

ក. បានចុះបញ្ជីការស្របច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា

ខ.មិនឋិតនៅក្រោមការហាមឃាត់ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាឬ ធនាគារអភិវឌ្ឍន៍អាស៊ី។

៦. ដើម្បីចាត់ទុកជាអ្នកដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់អ្នកទទួលការត្រូវ ៖

ក. ក្នុងរយៈពេល៣ឆ្នាំចុងក្រោយធ្លាប់បានបញ្ចប់កិច្ចសន្យាយ៉ាងតិចចំនួន២ នៃប្រភេទការងារប្រហាក់ប្រហែលគ្នាដែលកិច្ចសន្យានិមួយៗមានតម្លៃយ៉ាងតិច៧៥%នៃតម្លៃដាក់ដេញថ្លៃ។

ខ.ក្នុងរយៈពេល២ឆ្នាំចុងក្រោយធ្លាប់បានបញ្ចប់កិច្ចសន្យាដែលមានតម្លៃសរុបយ៉ាងតិចស្មើ ១.៥ ដង នៃតម្លៃដាក់ដេញថ្លៃ។

គ. អ្នកគ្រប់គ្រងសំណង់ដែលស្នើមកត្រូវមានបទពិសោធន៍យ៉ាងតិច៣ឆ្នាំ ក្នុងការត្រួតពិនិត្យការងារដែលមានលក្ខណៈប្រហាក់ប្រហែលនិងធ្លាប់មានតួនាទីជាអ្នកគ្រប់គ្រងការងារសំណង់ក្នុងរយៈពេលមិនតិចជាង១ឆ្នាំ។

*ឯកសារដែលជាភស្តុតាងបង្ហាញអំពីលក្ខណៈសម្បត្តិរបស់អ្នកដេញថ្លៃត្រូវដាក់ភ្ជាប់មកជាមួយសំណើដេញថ្លៃ។*

៧. សំណើដេញថ្លៃទាំងអស់ត្រូវដាក់មកអាស័យដ្ឋានខាងក្រោមនៅត្រឹមឬមុនម៉ោង **៩:០០ ថ្ងៃទី១១ ខែកក្កដា ឆ្នាំ ២០១៧**។ សំណើដេញថ្លៃណាដែលដាក់មកយឺត នឹងត្រូវបានបដិសេធចោល។ សំណើដេញថ្លៃដែលបានទទួលនឹងត្រូវបានបើកជាសាធាណៈភ្លាមៗ ក្រោយកាលបរិច្ឆេទផុតកំណត់នៅអាស័យដ្ឋានដដែល ដោយមានវត្តមានតំណាងអ្នកដេញថ្លៃទាំងអស់ ហើយអ្នកទទួលផលគម្រោង ពីសហគមន៍មូលដ្ឋានដែលពាក់ពន្ធ័ ដែលមានបំណងចង់ចូលរួម ត្រូវបានអនុញ្ញាតិអោយចូលរួមដោយផ្ទាល់ ។

***<u>អាស័យដ្ឋានសម្រាប់ដាក់សំណើដេញថ្លៃ និង បើកសំណើដេញថ្លៃ គឺៈ</u>***

អាស័យដ្ឋានៈ *សាលាស្រុកពាមជរ ស្ថិតក្នុងភូមិបង្កែក ឃុំស្វាយភ្លោះ ស្រុកពាមជរ ខេត្តព្រៃវែង*

បន្ទប់ៈ *បន្ទប់ប្រជុំក្រុមប្រឹក្សា សាលាស្រុកពាមជរ*

៨. ម្ចាស់គម្រោងនឹងផ្តល់កិច្ចសន្យាដល់អ្នកដេញថ្លៃណាដែលត្រូវបានពិនិត្យឃើញថាសំណើដេញថ្លៃមាន តម្លៃទាបជាងគេបំផុតនឹងឆ្លើយតបទាំងស្រុង ទៅតាមលក្ខខណ្ឌតម្រូវនានានៃឯកសារដេញថ្លៃ ហើយអ្នកដេញថ្លៃនោះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការអនុវត្តកិច្ចសន្យាដោយការពេញចិត្ត។

៩. សំណើដេញថ្លៃទាំងអស់ត្រូវភ្ជាប់មកជាមួយនូវលិខិតប្រកាសស្តីពីការធានាសំណើដេញថ្លៃ និងការអនុវត្តន៍កិច្ចសន្យា (bid and performance securing declaration) ដូចបានរៀបរាប់ក្នុងសេចក្តីណែនាំសម្រាប់អ្នកដេញថ្លៃ (Instructions to Bidders)។ ចំពោះសំណើដេញថ្លៃណាដែលមិនបានភ្ជាប់មកនូវលិខិតប្រកាសស្តីពីការធានាសំណើរដេញថ្លៃនិងការអនុវត្តន៍កិច្ចសន្យានេះ នឹងត្រូវបដិសេធចោលដោយចាត់ទុកថាមិនបានឆ្លើយតបតាមលក្ខខណ្ឌតម្រូវ ។

១០. ***<u>អាស័យដ្ឋានដើម្បីសាកសួរព័ត៌មាននិងទទួលយកឯកសារដេញថ្លៃគឺ</u>***

លោក ឈាង សុគា នាយករដ្ឋបាលសាលាស្រុក

អាស័យដ្ឋានៈ*សាលាស្រុកពាមជរ ស្ថិតក្នុងភូមិបង្កែក ឃុំស្វាយភ្លោះ ស្រុកពាមជរ ខេត្តព្រៃវែង*

អ៊ីម៉ែលៈ.<u>chanden@pvg.ncdd.gov.kh</u>

លេខទូរសព្ទ័ៈ 097-733 0412, 011-694 467

ម៉ោងការងារ ព្រឹកៈ ៨.៣០ -១០.៣០ , ល្ងាចៈ ២.៣០ -៤.៣០

១១. ក្នុងករណីដែលមានការលំបាកក្នុងការទទួលឯកសារដេញថ្លៃភាគីទាំងឡាយដែលមានចំណាប់អារម្មណ៍

អាចទាក់ទង ជាលាយលក្ខណ៍អក្សរមក

ឯកឧត្តម នី គឹមសាន, ប្រធានគម្រោង, លេខាធិការដ្ឋាន គ.ជ.អ.ប

អាសយដ្ឋានៈ មហាវិថីនរោត្តម ចំការមន ភ្នំពេញ

អ៊ីម៉ែលៈkimsanny1973@gmail.com

លេខទូរសព្ទៈ ០១១ ៩៧០ ៥៦៥

និងផ្ញើឯកសារដែលទំនាក់ទំនងនោះមួយច្បាប់ផងដែរទៅ

លោក យី សុខធារិទ្ធ

ប្រធាននាយកដ្ឋានសហប្រតិបត្តិការពហុភាគី

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ផ្លូវ ៩២, សង្កាត់វត្តភ្នំ, ខណ្ឌដូនពេញ, ភ្នំពេញ, កម្ពុជា

លេខទូរសព្ទៈ (៨៥៥) ២៣ ៧២៤ ៦៦៤

លេខទូរសព្ទដៃៈ (៨៥៥) ១២ ៥៨៥ ៩៥៩

អ៊ីម៉ែលៈ sokthearith_yi@mef.gov.kh

១២.រាជរដ្ឋាភិបាលកម្ពុជានិង ធនាគារអភិវឌ្ឍន៍អាស៊ីនឹងប្រកាសរៀងៗខ្លួនអំពីការដកសិទ្ធិទាំងស្រុងពីក្រុមហ៊ុន ដោយមិនកំណត់ពេល ឬក្នុងរយៈពេលកំណត់ណាមួយពីការទទួលបានកិច្ចសន្យាដែលប្រើ ប្រាស់មូលនិធិ រាជរដ្ឋាភិបាលកម្ពុជានិងធនាគារអភិវឌ្ឍន៍អាស៊ីប្រសិនបើនៅពេលណាមួយដែលពិនិត្យ ឃើញថាក្រុមហ៊ុន នោះជាប់ពាក់ព័ន្ធនឹងអំពើពុករលួយ ឬអំពើកេងបន្លំ អំពើឃុបឃិតឬអំពើបង្ខិតបង្ខំក្នុងការប្រកួតប្រជែង ដើម្បីទទួលបានកិច្ចសន្យាឬក្នុងពេល អនុវត្តកិច្ចសន្យា។

១៣. ភាគីពាក់ពន្ធ័អាចប្តឹងតវ៉ានៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការលទ្ធកម្ម ។ និតិវិធីនៃការប្តឹងតវ៉ាបាន រៀបរាប់ក្នុង *ប្រការ ២១* នៃ សេចក្តីណែនាំសម្រាប់អ្នកដេញថ្លៃ ។

យើងខ្ញុំរង់ចាំទទួលសំណើដេញថ្លៃពេញលេញនិងឆ្លើយតបតាមលក្ខខណ្ឌតម្រូវមុនកាលបរិច្ឆេទផុតកំណត់ ដែលបានបញ្ជាក់ខាងលើ និង តាមលក្ខខណ្ឌដែលបានរៀបរាប់ក្នុងឯកសារដេញថ្លៃ ។

ដោយសេចក្តីរាប់អាន!!!

សាលាស្រុក ពាមជរ ថ្ងៃទី 27 ខែ 06 ឆ្នាំ ២០១៧

ហត្ថលេខា និង ត្រា

ឈ្មោះ.............................

អភិបាលស្រុក.............................

សៅ ប្រុសិដ្ឋ